**BMI0094**

# សម្ភាសន៍ជាមួយឈ្មោះ យឿន ពិល ភេទប្រុស អាយុ៦៥ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ ដឹកស្បៀងស្រូវ
## សព្វថ្ងៃរស់នៅភូមិម៉ៅ ឃុំផ្កាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០
## សម្ភាសន៍ដោយៈ ស៊ិន សុធីតា

១ៈ០០ៈ៣៤

**១៩ទំព័រ**

ធីតាៈ អ៊ុំរៀនបានត្រឹមថ្នាក់ទីប៉ុន្មាន?

ពិលៈ រៀនបានថ្នាក់ទី៧ ។

ធីតាៈ ទី៧ពីសង្គមមែន?

ពិលៈ ពីសង្គម សម័យសីហនុ ។

ធីតាៈ អ៊ុំរៀនពីសម័យសង្គមនោះរៀននៅសាលាណា?

ពិលៈ រៀននៅសាលាស្វាយចេក ។

ធីតាៈ រៀននៅសាលាស្វាយចេក?

ពិលៈ បាទ!

ធីតាៈ សុំសួបន្តិចអ៊ុំឈ្មោះអីគេ?

ពិលៈ ឈ្មោះយឿន ពិល ។

ធីតាៈ អ៊ុំអាយុប៉ុន្មាន?

ពិលៈ អាយុ៦៥ឆ្នាំ ។

ធីតាៈ ស្រុកកំណើតនៅណា?

ពិលៈ ស្រុកកំណើតបច្ចុប្បន្ននៅនេះឯង ។

ធីតាៈ នៅហ្នឹងគេហៅភូមិអី?

ពិលៈ ភូមិម៉ៅ ។

ធីតាៈ ឃុំ?

ពិលៈ ឃុំផ្កាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។

ធីតាៈ ចុះឪពុកខ្ញុំឈ្មោះអីគេដែរអ៊ុំ?

ពិលៈ ឈ្មោះ យឿន តែគាត់ស្លាប់ហើយ ។

ធីតាៈ ចាំ! ម្ដាយ?

ពិលៈ ម្ដាយឈ្មោះ អឿយ គាត់ស្លាប់ដែរហើយ ។

ធីតាៈ គាត់ស្លាប់តាំងពីឆ្នាំណាដែរ?

ពិលៈ តាំងពីសម័យប៉ុល ពត កាលហ្នឹងមិនដឹងឆ្នាំប៉ុន្មានទេព្រោះកាលហ្នឹងរត់ទៅថៃ ។

ធីតាៈ អ៊ំ!

ពិលៈ កាលហ្នឹងដូចជាឆ្នាំ៧៧អីទេ កាលគាត់ស្លាប់ ។

ធីតាៈ អញ្ចឹង?

ពិលៈ បាទ!

ធីតាៈ ចុះអ៊ំដែលថាអ៊ំរៀនថ្នាក់ទី៧កាលហ្នឹងអ៊ំរៀនថ្នាក់ទី៧ហ្នឹងអត់មានបានបួសបានអីទេអ៊ំ?

ពិលៈ អត់ទេ អត់មានបានបួសទេ ។

ធីតាៈ ចាំ! រៀននៅសាលាស្វាយចេក?

ពិលៈ រៀននៅស្វាយចេក! កាលហ្នឹងរៀននៅសាលាស្វាយចេកស្មើរហ្នឹងបាក់ឌុបសព្វថ្ងៃ ។

ធីតាៈ អញ្ចឹងអ៊ំរៀនបានច្រើនដែរ?

ពិលៈ បាទ!

ធីតាៈ ចុះរៀនហ្នឹងមានកូនសិស្សប៉ុន្មាននាក់ដែរ?

ពិលៈ ដែលរៀនហ្នឹងក្នុងមួយថ្នាក់មាន៤២នាក់ ។

ធីតាៈ ក្នុងមួយថ្នាក់មាន៤២នាក់?

ពិលៈ ដែលរៀនជាមួយខ្ញុំហ្នឹងមាន៤២នាក់ ។

ធីតាៈ គ្រូពីខាងណាដែរ?

ពិលៈ គ្រូនៅស្វាយចេកហ្នឹង! កាលគេបង្រៀនហ្នឹងសម័យរាជានិយម ហើយបង្រៀនហ្នឹងមិនមែនដូចសព្វថ្ងៃទេ ។

ធីតាៈ ចាំ! អ៊ំនិយាយម៉ោ កាលហ្នឹងអ៊ំរៀនបានអីគេខ្លះកាលនៅសម័យហ្នឹង ហើយអ៊ំចេះដឹងអីគេខ្លះអញ្ចឹងណាំ?

ពិលៈ មានបានដឹងអីទេ ខ្ញុំបានត្រឹមតែម៉ារៀន ហើយកាលហ្នឹងខ្ញុំឈប់រៀនទៅធ្វើស្រែធ្វើចំការទៅ ។

ធីតាៈ អ៊ំ! ចុះអ៊ំមានធ្លាប់ចូលបដិវត្តន៍ចូលអីទេអ៊ំ?

ពិលៈ អត់ទេ!

ធីតាៈ អត់មានដែលបានចូលរួមទេ?

ពិលៈ អត់ទេ!

ធីតាៈ ចាំ!

ពិលៈ ដល់ពេលសម័យ៧០ហ្នឹងរដ្ឋប្រហា កាលហ្នឹងខ្ញុំនៅដែរ នៅដល់សម័យ៧៧ ។

ធីតាៈ រដ្ឋប្រហា?

ពិលៈ កាលហ្នឹងរដ្ឋប្រហាឆ្នាំ៧០ ។

ធីតាៈ អ៊ំទៅណា?

ពិលៈ ខ្ញុំរត់ទៅថៃ ទេកាលហ្នឹងរត់ទៅថៃឆ្នាំ៧៧ ។

ធីតាៈ អញ្ចឹងរដ្ឋប្រហាទៅណាវិញ?

ពិលៈ ខ្ញុំរត់ទៅថៃ ។

ធីតាៈ អញ្ចឹងរត់តាំងពីរដ្ឋប្រហាហ្នុង?

ពិលៈ ឆ្នាំ៧០រដ្ឋប្រហា ៧១,៧២,៧៣,៧៤,៧៥ខ្ញុំបម្រើប៉ុល ពតបានរយៈពេល៥ឆ្នាំដែរ ដល់ពេលឆ្នាំ៧៧ខ្ញុំរត់ទៅថៃ ។

ធីតាៈ អញ្ចឹងកាល៧១,៧២ហ្នឹងអ៊ំបម្រើប៉ុល ពត?

ពិលៈ ហ្នឹងអើយ ។

ធីតាៈ កាលឆ្នាំ៧១ហ្នឹងអ៊ំបម្រើអីគេខ្លះ?

ពិលៈ គេឲ្យយើងកើបអាចម៍គោអាចមន៍អីហ្នឹង គេឲ្យយើងរែកដី អាអាចមន៍មនុស្សហ្នឹងយកទៅធ្វើជី

ធីតាៈ កាល៧១ហ្នឹងដូចសម័យរដ្ឋប្រហាមែនទេ កាលហ្នឹងរដ្ឋប្រហាទម្លាក់សម្តេច?

ពិលៈ អាហ្នឹងរដ្ឋប្រហា ដល់៧៥នេះបានសម័យប៉ុល ពត ។

ធីតាៈ កាល៧៥ហ្នឹងធ្វើអីគេខ្លះទៅអ៊ំ?

ពិលៈ កាលហ្នឹងគេឲ្យខ្ញុំទៅភ្នូរទៅរាស់ ដល់ម៉ោដល់សម័យ៧៦,៧៧នេះបានរបបប្រល័យពូជសាសន៍នេះដូចថាជម្លៀសនូវយុទ្ធនាការសិស្សឬយុទ្ធនាការយោធាទាហាន ប៉ុន្តែគេលុបចោល ។

ធីតាៈ ចុះគេជម្លៀសអ៊ំទៅណាវិញ?

ពិលៈ គេមានជម្លៀសខ្ញុំណា ខ្ញុំរត់ទៅថៃហ្នុង ។

ធីតាៈ ឆ្នាំ៧៥ហ្នឹងអ៊ំរត់ទៅថៃ?

ពិលៈ អត់ទេ!

ធីតាៈ ឆ្នាំ៧៧?

ពិលៈ បាទ!

ធីតាៈ ចុះ៧៥អ៊ំនៅណា?

ពិលៈ នៅលើកទំនប់អាងត្រពាំងថ្ម អាងអីណាគេទេ ។

ធីតាៈ អញ្ចឹង៧៥ហ្នឹងអ៊ំនៅលើកទំនប់នៅអាងត្រពាំងថ្ម?

ពិលៈ ត្រពាំងថ្ម ដើងគ្រោះ ។

ធីតាៈ លើកទំនប់នៅអាងត្រពាំងថ្មបានរយៈពេលប៉ុន្មាន?

ពិលៈ រយៈពេលមួយខែ ។

ធីតាៈ ចុះមួយខែក្រោយម៉ោធ្វើអីទៀត?

ពិលៈ ក្រោយម៉ោគេប្តូរខ្ញុំឲ្យដឹកស្បៀងឲ្យគេ ដឹកស្បៀងឲ្យអ្នកនៅដើងគ្រោះ ។

ធីតាៈ អ្នកណាគេដែលគ្រប់គ្រងនៅកន្លែងហ្នឹងអ៊ំ?

ពិលៈ អត់ស្គាល់ផង ធម្មតាយើងប្រជាជនគេមិនឲ្យទៅជិតផង ។

ធីតាៈ ចុះការងារនៅហ្នឹងម៉េចដែរមើលទៅ?

ពិលៈ ការងារ?

ធីតាៈ ចា៎!

ពិលៈ គេប្រើយើងធ្ងន់ធ្ងរបំផុតហើយ យើងមួយនាក់មួយម៉ែត្រធ្វើម៉េចឲ្យហើយ ប្រើគ្នាគ្មានគិតសុខភាពទេ ។

ធីតាៈ ចុះអ៊ំដូចថាក្រៅពីធ្វើការងារហ្នឹង អ៊ំមានដែលឃើញគេសម្លាប់មនុស្សផ្ទាល់ភ្នែកទេ?

ពិលៈ រឿងសម្លាប់នោះមិនដែលឃើញទេ ប៉ុន្តែឮគេថា! កាលឆ្នាំ៧៧ឮតែគេថាយកទៅសម្លាប់តែមិនដឹងថាគេសម្លាប់ឬក៏អត់នោះទេ មានតែយុទ្ធនាការ ។

ធីតាៈ យុទ្ធនាការអីគេ?

ពិលៈ យុទ្ធនាការសិស្ស ដឹងតែរឿងប្រវត្តិសាស្ត្រ ។

ធីតាៈ អ៊ំ!អ៊ំកាលហ្នឹងដូចថាឲ្យតែអ្នកចេះដឹងគេយកមែន?

ពិលៈ ហ្នឹងអើយគេយក ។

ធីតាៈ គេយកម៉េចខ្លះទៅអ៊ំជួយរៀបរាប់បន្តិចបានទេ?

ពិលៈ គេយកហ្នឹងគេរៀននយោបាយ ហើយរៀនហ្នឹងឲ្យមានរបបកម្មុយនីស សូម្បីតែកណ្តៀវអត់មាននៅក្នុងផ្ទះទេគឺដាក់រួមទាំងអស់អាហ្នឹងទី១ ហើយទី២គេថាអ្នកណាដែលសម្លាប់ហ្នឹងគឺគេត្រូវដកចេញ ។

ធីតា៖ ខាងណាអ្នកដក?

ពិល៖ ប៉ុល ពតជាអ្នកដកណា៎ ។

ធីតា៖ កាលហ្នឹងនៅឆ្នាំណា?

ពិល៖ ឆ្នាំ៧៦ ។

ធីតា៖ កាល៧៦ហ្នឹងអ៊ីដកទៅខាងណាវិញ?

ពិល៖ កាលហ្នឹងដកឲ្យទៅដឹកស្បៀងហ្នឹង ។

ធីតា៖ ដឹកស្បៀងដឹកតាមរយៈអីគេ?

ពិល៖ ដឹករទេះគោ ។

ធីតា៖ ដឹករទេះគោ?

ពិល៖ បាទ!

ធីតា៖ ដឹកពីណាទៅណា?

ពិល៖ ពីភូមិទៅដល់បន្ទាយឆ្មា ។

ធីតា៖ ពីភូមិអីគេអ៊ី?

ពិល៖ ពីភូមិហ្នឹងទៅដល់បន្ទាយឆ្មា ។

ធីតា៖ អ៊ំឆ្ងាយណា៎!

ពិល៖ ឆ្ងាយ!

ធីតា៖ ហើយម៉ាររទេះប៉ុន្មានទៅ ស្រូវ ស្បៀងអីហ្នឹង?

ពិល៖ តែបីបាវហ្នឹង ។

ធីតា៖ តែបីបាវទេ?

ពិល៖ បាទ!

ធីតា៖ ក្នុងហ្នឹងមានតែអ៊ំទេ អត់មានអ្នកផ្សេងដឹកជាមួយទេ?

ពិល៖ មានអ្នកផ្សេងតែខ្ញុំអត់ស្គាល់គាត់ទេព្រោះកាលសម័យនោះនិយាយជាមួយគ្នាអីអត់បានទេ ។

ធីតា៖ ហើយក្នុងមួយថ្ងៃគេអត់មានកំណត់ថាប៉ុន្មានអីប៉ុន្មានអត់ទេ?

ពិល៖ អត់ទេ គេអត់មានកំណត់ទេ ហើយដឹកទៅឲ្យគេអត់មានពេលមានម៉ោងថាត្រូវម៉ោងប៉ុន្មានដឹកយកឲ្យគេអត់ទេ ។

ធីតា៖ ហើយពេលអ៊ំដឹកហ្នឹងមានប៉ុន្មានរទេះទៅដែលដឹកពីភូមិម៉ោទៅបន្ទាយឆ្មាហ្នឹង?

ពិល៖ មានតាមក្រុមរបស់គេ ។

ធីតា៖ អ៊ំក្រុមទីប៉ុន្មាន?

ពិល៖ ភ្លេចអស់ហើយអារឿងក្រុមហ្នឹង គេឲ្យដឹកចេះតែដឹកទៅ ព្រោះវាយូពេកហើយវាភ្លេចអស់ហើយ ។

ធីតា៖ អញ្ចឹងក្រុមគ្រួសាររបស់អ៊ំអត់មានបានជួបជុំគ្នាផង?

ពិល៖ ពេលណា?

ធីតា៖ កាលឆ្នាំ៧៦អត់មានបានជួបជុំគ្នាផង?

ពិល៖ ជុំគ្នារហូតម៉ោដល់សព្វថ្ងៃ ។

ធីតា៖ អញ្ចឹងមានតែអ៊ំទេដែលចាប់ទៅបន្ទាយឆ្មា?

ពិល៖ បាទដឹកស្បៀងឲ្យគេ ។

ធីតា៖ ដឹកស្បៀងហ្នឹងអត់មានកំណត់ថាឲ្យដឹកប៉ុន្មានអីប៉ុន្មានទេ?

ពិល៖ អត់ទេ បើគេត្រូវការគេហៅទៅបើគេមិនត្រូវការទេអត់ទៅ ។

ធីតា៖ ចុះក្រោយពីការងារដឹកស្បៀងធ្វើអីទៀតអ៊ំ?

ពិល៖ ក្រៅការងារហ្នឹងធ្វើបន្លែធ្វើអីទៀតទៅ អត់មានបានស្រួលទេ ។

ធីតា៖ មានកងឈ្លបម៉ោចាំត្រួតពិនិត្យអីអត់?

ពិល៖ កងឈ្លបវាមានតែសុទ្ធតែជាអ្នកផ្សេងហ្នឹង មិនស្គាល់ឈ្មោះទេ ហើយមិនហ៊ានមើលមុខទៀត ។

ធីតា៖ ភាគច្រើនកងឈ្លបហ្នឹងចាស់ឬក្មេង?

ពិល៖ សុទ្ធតែក្មេងហ្នឹង ។

ធីតា៖ អញ្ចឹងអ៊ំទៅស្រុកបន្ទាយឆ្មាហ្នឹងរយៈពេលប៉ុន្មានដែរ?

ពិល៖ មិនកំណត់ទេ ក្រោយពីចល័តហើយហ្នឹងម៉ោហ្នុងមិនកំណត់ថាប៉ុន្មានខែទេ ។

ធីតា៖ អង្គការឲ្យអ៊ំទៅខាងកងចល័តមែន?

ពិល៖ ខាងដឹកជញ្ជូន ។

ធីតា៖ ទៅខាងដឹកជញ្ជូន?

ពិល៖ ខាងដឹកជញ្ជូនមិនបានលើកទំនប់ដូចគេទេ ។

ធីតា៖ ចំងាយប៉ុន្មានទៅពីហ្នឹងទៅស្រុកបន្ទាយឆ្មា ប៉ុន្មានគីឡូទៅ?

ពិល៖ ពីនេះទៅប្រហែលជា២០គីឡូទៅចុះ ។

ធីតា៖ អញ្ចឹងអ្នកដែលចាត់ចែងឲ្យអ៊ំទៅបន្ទាយឆ្មាអ៊ំអត់មានចាំឈ្មោះទេ?

ពិល៖ អត់ចាំឈ្មោះទេ ។

ធីតាៈ មានអ្នកក្រោមហ្នឹងទៀតអត់?

ពិលៈ មិនចាំទេព្រោះវាឡើង២០ឆ្នាំហើយវាភ្លេចអស់ហើយ ។

ធីតាៈ ចុះអ៊ំដូចទាក់ទងទៅនឹងពេលដែលអ៊ំទៅដឹកដល់បន្ទាយឆ្មាហ្នឹងស្ថានភាពនៅក្នុងភូមិហ្នឹងយ៉ាងម៉េចដែរ?

ពិលៈ បន្ទាយឆ្មាហ្នឹង?

ធីតាៈ ចាំ!

ពិលៈ មើលទៅជីវភាពរស់នៅរបស់ពួកគេខ្ញុំមិនដឹងទេ ។

ធីតាៈ ចាំ! នៅបន្ទាយឆ្មាហ្នឹងអ៊ំអត់មានដឹងថាអ្នកណាជាអ្នកគ្រប់គ្រងទេ?

ពិលៈ អត់ទេ ។

ធីតាៈ គ្រាន់តែដឹងថាយើងជាអ្នកដឹកទេ?

ពិលៈ ខ្ញុំមិនមែនជាអ្នកគ្រប់គ្រងទេ ។

ធីតាៈ គ្រាន់តែយើងជាអ្នកដឹកជញ្ជូនទេ?

ពិលៈ គ្រាន់តែជួបជុំកូនចៅហ្នឹងមិនហ៊ានមើលផង ។

ធីតាៈ ចាំ! កាលហ្នឹងអ៊ំអាយុប៉ុន្មានដែរកាលដឹកស្បៀងដឹកអីហ្នឹង?

ពិលៈ អាយុ៣៥ ។

ធីតាៈ ហើយអ៊ំនៅសហករណ៍ណាដែរ?

ពិលៈ មិនដឹងសហករណ៍អីភ្លេចឈ្មោះបាត់ហើយ ។

ធីតាៈ តំបន់អីគេ?

ពិលៈ តំបន់៥ ។

ធីតាៈ អ៎នៅតំបន់៥?

ពិលៈ ហ្នឹងអើយ!

ធីតាៈ តំបន់៥ នៅស្រុកអីគេអ៊ំ?

ពិលៈ នៅស្រុកថ្មពួក ។

ធីតាៈ អញ្ចឹងមានន័យខ្មែរក្រហមជម្លៀសអ៊ំទៅស្រុកថ្មពួក?

ពិលៈ ជម្លៀសទៅហើយត្រលប់ម៉ោវិញ ពេលជម្លៀសទៅហើយគេឲ្យត្រលប់ម៉ោវិញ ។

ធីតាៈ ចុះរយៈពេលប៉ុន្មានដែលអ៊ំថាម៉ោនៅស្រុកថ្មពួក ហើយម៉ោភូមិម៉ោវិញ ដល់ពេលម៉ោភូមិម៉ោហើយទៅស្រុកបន្ទាយឆ្មាទៀត?

ពិលៈ  អត់ទេនៅភូមិម៉ៅរហូតហ្នឹង ។

ធីតាៈ  ចុះនៅតំបន់៥ហ្នឹងអ៊ំឃើញមានប្រជាជនរស់នៅច្រើនទេ?

ពិលៈ  ច្រើនណាស់ ។

ធីតាៈ  ប៉ុន្មានគ្រួសារទៅ?

ពិលៈ  អ្នកណាទៅដឹង ។

ធីតាៈ  តែបើយើងប៉ាន់ស្មានថាមានប្រជាជនប្រហែលប៉ុន្មានរស់នៅហ្នឹង?

ពិលៈ  រស់នៅណា?

ធីតាៈ  នៅតំបន់៥ហ្នឹង?

ពិលៈ  រាប់ម៉ឺនរាប់ពាន់គ្រួសារ  ច្រើនណាស់ព្រោះតំបន់៥ច្រើនណាស់ ។

ធីតាៈ  ភាគច្រើនប្រជាជននៅហ្នឹងគេឲ្យធ្វើអីខ្លះ?

ពិលៈ  មានលើកទំនប់  ជីកប្រលាយ  ធ្វើអ្វីស្រេចតែលើគេប្រើ  ខ្ញុំប្រាប់មិនត្រូវទេ ។

ធីតាៈ  ចុះការងារក្រៅពីជីកជញ្ជូនគេឲ្យធ្វើអីទៀត?

ពិលៈ  ស្រេចតែលើគេប្រើ ។

ធីតាៈ  ធ្វើអីគេខ្លះទៅអ៊ំ?

ពិលៈ  លើកទំនប់  ជីកប្រលាយ ។

ធីតាៈ  ហើយធ្វើអីទៀត?

ពិលៈ  ប៉ុណ្ណឹង ។

ធីតាៈ  ចុះកាលឆ្នាំ៧៧វិញអ៊ំ?

ពិលៈ  កាលឆ្នាំ៧៧គេថាគេត្រូវវៃរបប  វៃរបបទាំងអស់  ដល់ពេលវៃរបបខ្ញុំនឹកឃើញថាប្រហែលជាមិនរស់ទេខ្ញុំក៏រត់ទៅថៃ ។

ធីតាៈ  រត់ទៅថៃ?

ពិលៈ  បាទ!

ធីតាៈ  ទៅដល់ប្រទេសថៃហ្នឹងឬក៏គ្រាន់តែទៅដល់ត្រឹមព្រំប្រទល់ទេ?

ពិលៈ  ទៅដល់ស្រុកតាបដ្ឋា ។

ធីតាៈ  ស្រុកតាបដ្ឋា?

ពិលៈ  ហ្នឹងអើយ ។

ធីតាៈ  បច្ចុប្បន្នគេហៅស្រុកអីគេ?

ពិលៈ តាបផ្ទា ។

ធីតាៈ ចុះកាលពីសម័យមុន?

ពិលៈ តាបផ្ទា ។

ធីតាៈ តាបផ្ទាដូចគ្នា?

ពិលៈ ហ្នឹងអើយ ។

ធីតាៈ ហ្នឹងខេត្តអីគេ?

ពិលៈ មិនដឹងខេត្តអីគេទេ ។

ធីតាៈ អ៊ំចេញពីណាទៅបានទៅដល់តាបផ្ទាហ្នឹង?

ពិលៈ ដើរឆ្លងកាត់នេះ ដើរទាំងយប់ទាំងថ្ងៃ ។

ធីតាៈ ទៅគ្នាប៉ុន្មាននាក់?

ពិលៈ ទៅគ្នា៨នាក់ ។

ធីតាៈ ៨នាក់ហ្នឹងគាត់ធ្វើអីគេ?

ពិលៈ គេអត់មានធ្វើអីទេ គ្រាន់តែគេខ្លាចគេវ៉ៃចោលដល់ហើយចេះតែនាំគ្នារត់ទៅ ។

ធីតាៈ ហេតុអីបានជាអ៊ំសម្រេចទៅខាងហ្នឹងវិញ?

ពិលៈ បើសិនជាខ្ញុំនៅវាត្រូវស្លាប់ សម្រេចចិត្តហ្នឹងហេងសយទេ ។

ធីតាៈ ហើយអ៊ំសម្រេចទៅហ្នឹងដូចអង្គការអើអត់ដឹងទេ អាហ្នឹងយើងលួចទៅឬក៏យើងសម្រេចចិត្តទៅខ្លួនឯង?

ពិលៈ យើងទៅដោយខ្លួនឯង ។

ធីតាៈ ទៅហ្នឹងមានស្រីមានប្រុសទៅទេ?

ពិលៈ ទេអត់មានស្រីទេ ។

ធីតាៈ មានតែប្រុសៗ?

ពិលៈ ហ្នឹងអើយ ។

ធីតាៈ អ្នកស្រុកភូមិស្គាល់គ្នាមែន?

ពិលៈ មិនដឹងអ្នកភូមិណាភូមិណីចេះតែរត់ទៅជាមួយគ្នាបាន៨នាក់ តែក្រោយម៉ោបែកបាក់គ្នាអស់ហើយមិនបានជួបជុំគ្នាទេ ។

ធីតាៈ ចុះអ៊ំថាធ្លាប់ធ្វើទ័ពធ្វើអីហ្នឹងអាហ្នឹងធ្វើអីគេអ៊ំ?

ពិលៈ សម័យ៧៧ហ្នឹងខ្ញុំចូលបម្រើកងទ័ព កងទ័ពខាងប៉ុល ពត ។

ធីតាៈ  រត់ទៅហើយធ្វើកងទ័ពខាងប៉ាវ៉ាទៀតមែនអ៊ំ?

ពិលៈ  កាលហ្នឹងរត់ទៅជិតដល់តាបផ្កាហើយ  គេដាក់ទៅក្រសួងហិរញ្ញដល់ហើយត្រលប់ម៉ោវិញទៅ ។

ធីតាៈ  ខាងណាអ្នកយកអ៊ំត្រលប់ម៉ោវិញ?

ពិលៈ  យើងអ្នកត្រលប់ម៉ោវិញ ។

ធីតាៈ  អ៎អ៊ំត្រលបម៉ោវិញ?

ពិលៈ  ហ្នឹងអើយ ។

ធីតាៈ  អញ្ចឹងទៅដល់ប្រទេសថៃហ្នឹងបានរយៈពេលប៉ុន្មាន?

ពិលៈ  នៅបាន១ខែ ។

ធីតាៈ  នៅបាន១ខែ?

ពិលៈ  អាហ្នឹងដែលធ្វើទាហានហ្នឹង ។

ធីតាៈ  ចា៎! ខាងណាអ្នកគ្រប់គ្រង?

ពិលៈ  តាសឹន សាន ។

ធីតាៈ  តាសឹន សាន អញ្ចឹងពេលធ្វើទ័ពនៅហ្នឹងគ្រប់គ្រងគ្នាប៉ុន្មាននាក់ដែរ?

ពិលៈ  ទាំងអស់៣០០នាក់ ។

ធីតាៈ  ៣០០នាក់ហ្នឹងអ៊ំខាងទ័ពអីគេ?

ពិលៈ  ខ្ញុំខាងប្រយុទ្ធ ។

ធីតាៈ  ខាងប្រយុទ្ធ?

ពិលៈ  ហ្នឹងអើយ ។

ធីតាៈ  ប្រយុទ្ធពីណាទៅណាអ៊ំ?

ពិលៈ  យើងចេះតែប្រយុទ្ធ  យើងតម្រូនយោបាយដើម្បីខ្មែរទេ  បើយួនវ៉ៃយើងវ៉ៃយួនវិញដូចតែគ្នា
ហ្នឹង  វ៉ៃអញ្ចឹងឯងប៉ាវ៉ាអត់មានរើសមុខទេ  ដើម្បីសេរីភាព  ដើម្បីសិទ្ធរបស់ខ្មែរណា៎ ។

ធីតាៈ  អញ្ចឹងអ៊ំមានគ្នា៣០០នាក់ដែរ?

ពិលៈ  ៣០០នាក់ ។

ធីតាៈ  ៣០០នាក់ហ្នឹងពីខាងណាម៉ោវិញ?

ពិលៈ  ទៅពីនេះឯង ។

ធីតាៈ  ទៅពី?

ពិលៈ  ទៅខ្មែរយើងនេះឯង ។

ធីតាៈ ខ្មែរយើងវាមានខេត្តណាស្រុកណាអញ្ចឹងណាអ៊ំ?

ពិលៈ មិនដឹងរឿងស្រុកខេត្តទេកាលហ្នឹង ព្រោះវាម៉ោគ្រប់ខេត្តគ្រប់ស្រុក តាំងពីកំពង់ចាម កំពតណាណីចេះតែម៉ោទៅ អាខ្ញុំនិយាយខ្មែរមិនច្បាស់ផង ។

ធីតាៈ អ៊ំថាមានគ្នា៣០០នាក់ទៅប្រយុទ្ធនៅខាងណាវិញ?

ពិលៈ ប្រយុទ្ធនៅតាមជាយដែនហ្នឹង ។

ធីតាៈ ជាយដែន?

ពិលៈ ហ្នឹងអើយ ។

ធីតាៈ នៅតាមព្រំប្រទល់អីគេអាហ្នឹង?

ពិលៈ ព្រំប្រទល់ខ្មែរ ។

ធីតាៈ ព្រំប្រទល់ខ្មែរ?

ពិលៈ បាទ!

ធីតាៈ ខាងបន្ទាយឆ្មារមែន?

ពិលៈ ខាងបន្ទាយឆ្មាគេផ្សេង ហើយខ្ញុំខាងស្វាយចេក ។

ធីតាៈ ខាងស្វាយចេកហ្នឹងអ៊ំ?

ពិលៈ បាទ!

ធីតាៈ រយៈពេលប៉ុន្មានដែរអ៊ំ?

ពិលៈ ប្រយុទ្ធហ្នឹង?

ធីតាៈ ចា៎!

ពិលៈ មិនយូរទេប្រហែលជា៣ទៅ៤ម៉ោងហ្នឹងដកថយវិញហើយ ។

ធីតាៈ អញ្ចឹងឆ្នាំ៧៧ហ្នឹងអ៊ំចាប់ផ្តើមប្រយុទ្ធហើយ?

ពិលៈ កាល៧៧?

ធីតាៈ កាល៧៧រត់ទៅថៃហើយត្រលប់ម៉ោវិញរយៈពេលបានមួយខែ?

ពិលៈ ដល់ពេល៧៩បានចាប់ផ្តើមមានកងទ័ពនៅខាងជាយដែន កាល៧៧ហ្នឹងខ្ញុំរត់ទៅជាប់គុកជាប់ខ្នោះជាប់ឃ្នាងខ្ញុំគេយកម៉ោវិញទៅយកម៉ោធ្វើទ័ព ។

ធីតាៈ អ៊ំជាប់ខ្នោះអីគេ ហើយជាប់នៅខាងណា ហើយនៅប៉ុន្មានដែលអ៊ំជាប់ខ្នោះ?

ពិលៈ ជាប់នៅឆ្នាំ៧៧ កាលហ្នឹងជាប់នៅស្រុកថៃណា៎ ហើយគេឲ្យបាយយើងស៊ីធម្មតា គេមិនដាក់គុកយើងទេតែគេឲ្យយើងស៊ីធម្មតា គ្រាន់ថាវាដូចជាប់គុកអញ្ចឹងព្រោះវាអត់មានសេរីភាព ។

ធីតាៈ ជាប់ខ្នោះទាំងអស់គ្នា ចំនួនគ្នា៨នាក់ហ្នឹងឬក៏តែអ៊ំម្នាក់ឯង?

ពិលៈ អត់មានជាប់គុកជាប់ខ្នោះអីទេ គ្រាន់ថាអត់មានសេរីភាព យើងស៊ីចុកធម្មតាប៉ុន្តែយើងអត់មាន សេរីភាពដើរហើរទៅទីជិតឬទីឆ្ងាយទេគឺនៅមួយកន្លែង ។

ធីតាៈ អញ្ចឹងអ៊ំខ្ញុំសុំសួតទៅទៀតណា៎?

ពិលៈ សួចុះ ។

ធីតាៈ ដូចថាអ៊ំនៅស្វាយចេករយៈពេលបីម៉ោងហ្នឹងយ៉ាងម៉េចដែរ?

ពិលៈ ម៉េច?

ធីតាៈ វៀត្នាហ្នឹងណា៎ ដែលវៀត្នានៅស្វាយចេកណាមានកងទ័ពណាខ្លះដែលវៀត្នា?

ពិលៈ ទ័ពខ្មែរជាមួយទ័ពកម្ពុជា ។

ធីតាៈ កម្ពុជា?

ពិលៈ បាទ!

ធីតាៈ រដ្ឋកម្ពុជាខាងណាជាអ្នកគ្រប់គ្រង?

ពិលៈ ហ៊ុន សែន ។

ធីតាៈ ហ៊ុន សែន?

ពិលៈ ប្រធានធំ ។

ធីតាៈ អ៊ំ! ប៉ុន្តែអត់មានឃើញគាត់ចូលរួមជាមួយដែរទេ?

ពិលៈ អាស៎?

ធីតាៈ រដ្ឋកម្ពុជាហ្នឹងខាងហ៊ុន សែនជាអ្នកគ្រប់គ្រង?

ពិលៈ អ្នកគ្រប់គ្រងៗ ។

ធីតាៈ អញ្ចឹងអ៊ំវៀត្នានៅស្រុកស្វាយចេកហ្មង?

ពិលៈ បាទ!

ធីតាៈ ហើយដូចថានៅស្រុកស្វាយចេកហ្នឹង វៀត្នាទាំងព្រឹកទាំងល្ងាចហ្មង?

ពិលៈ ឲ្យតែដល់ម៉ោង៨វៀត្នាហើយ ។

ធីតាៈ ឲ្យតែដល់ម៉ោង៨វៀត្នាហើយ?

ពិលៈ ហ្នឹងអើយ ម៉ោង៨ទាបភ្លឺ ។

ធីតាៈ ប្រយុទ្ធហ្នឹងមានអីគេខ្លះទៅ?

ពិលៈ រឿងកាំភ្លើងមែន?

ធីតាៈ ចាំ!

ពិលៈ ខាងខ្ញុំមានត្រៀម៦០មីលីម៉ែត ៧០មីលីម៉ែត។

ធីតាៈ កាំភ្លើងមែន?

ពិលៈ ហ្នឹងអើយ។

ធីតាៈ កាំភ្លើងអីគេ?

ពិលៈ កាំភ្លើងអាការ។

ធីតាៈ មានគ្រប់ៗដៃហ្នឹង?

ពិលៈ មានគ្រប់ៗគ្នា។

ធីតាៈ ចុះអ៊ំកាន់កាំភ្លើងអីគេដែរអ៊ំ?

ពិលៈ កាន់កាំភ្លើងប៉េអា។

ធីតាៈ ហើយពេលហ្នឹងអ៊ំជាអ្នកដឹកនាំមុខគេមែន?

ពិលៈ ខ្ញុំដឹកនាំមុខគេរហូត។

ធីតាៈ ហើយពេលដឹកនាំអញ្ចឹងដូចថាឲ្យយើងវ៉ៃទៅមុខហ្នឹងមាននិយាយអីគេខ្លះ?

ពិលៈ ខ្ញុំអ្នកដឹកនាំគេតែអ្នកធំនៅពីក្រោយខ្នង បញ្ជាម៉ោកន្លែងធំនោះ។

ធីតាៈ កន្លែងណាវិញជាអ្នកបញ្ជា?

ពិលៈ នៅជាយដែននោះហ្នឹង។

ធីតាៈ គាត់ឈ្មោះអីគេ?

ពិលៈ ឈ្មោះ ហែម ពុ តែគាត់ងាប់អស់ហើយ។

ធីតាៈ ចុះអ៊ំអត់មានដាក់តួនាទីថាអ៊ំជាវរៈសេនីយ៍អីទេ?

ពិលៈ កាលពីមុនជាវរៈសេនីយ៍ដល់រំសាយម៉ោអត់មានអីទៀតទេ។

ធីតាៈ កាលអ៊ំដឹកនាំអ៊ំមានតួនាទីជាអីគេ?

ពិលៈ ជាវរៈសេនីយ៍។

ធីតាៈ ជាវរៈសេនីអីគេ?

ពិលៈ វរៈសេនីយ៍ត្រី។

ធីតាៈ អញ្ចឹងអ៊ំមានតួនាទីជាវរៈសេនីយ៍ត្រីដឹកនាំអញ្ចឹងទៅ?

ពិលៈ បាទ!

ធីតាៈ ហើយវ៉ៃគ្នាហ្នឹងរយៈពេលតែ៣ម៉ោងទេអ៊ំ?

ពិលៈ មិនទៀងទេ ៣ម៉ោងក៏មាន ១ម៉ោងក៏មាន ៥ម៉ោងក៏មានវាអត់ទៀង។

ធីតាៈ វៃជាមួយរដ្ឋកម្ពុជាហ្នឹង?

ពិលៈ ហ្នឹងអើយ។

ធីតាៈ ហើយវៃហ្នឹងវៃរហូតហ្នងអត់មានថាសម្រាកអីដកទ័ពអីទេ?

ពិលៈ សម្រាក និយាយគ្នាបាន យើងសម្រាកហូបបាយទៅទឹកដូចគ្នា យើងខ្មែរដូចគ្នានិយាយគ្នាបាន តែបើយួននោះវាស្ដាប់ខ្មែរមិនបាន ខ្មែរគ្នាឯងស្ដាប់បាន យើងថាសម្រាកសិនទៅគេសម្រាក ហើយដល់ពេលវៃក៏វៃទៅ ហើយចូលសុទ្ធតែបងប្អូន។

ធីតាៈ អញ្ចឹងនៅក្នុងឆ្នាំ៧៧ហ្នឹងហ្នង?

ពិលៈ អត់ទេកាលវៃហ្នឹងនៅឆ្នាំ៨៤,៨៥ហ្នឹងឯង។

ធីតាៈ អាហ្នឹងវៃនៅណា?

ពិលៈ អា៧៧ហ្នឹងខ្ញុំរត់ហ្នឹង។

ធីតាៈ ចុះ៧៨អ៊ំធ្វើអី?

ពិលៈ ពេល៧៨ហ្នឹងខ្ញុំរត់ទៅផុតហើយហ្នឹង។

ធីតាៈ ចុះពេល៧៩វៀតណាមចូលវិញ?

ពិលៈ ខ្ញុំធ្វើទ័ពហើយ កាលហ្នឹងធ្វើទ័ពប៉ុរ៉ាហ្នឹងត្រលប់ម៉ោវិញវៃជាមួយខ្មែរក្រហមហ្នឹង។

ធីតាៈ ធ្វើជាទាហានប៉ុរ៉ាវៃជាមួយទ័ពខ្មែរក្រហម?

ពិលៈ វៃជាមួយខ្មែរក្រហមផង វៃជាមួយទ័ពយួនផង។

ធីតាៈ វៃនៅខាងណាអ៊ំ?

ពិលៈ នៅម្ដុំជាយដែននេះឯង។

ធីតាៈ នៅជាយដែនស្រុកស្វាយចេកមែន?

ពិលៈ បាទ!

ធីតាៈ វៃហ្នឹងបញ្ជូនទៅរហូតមែន?

ពិលៈ បញ្ជូនម៉េច?

ធីតាៈ ដូចថាពេលយើងវៃអញ្ចឹងទៅយើងចេះតែទៅមុខទៅមុខទៀតមែន?

ពិលៈ កាលប្រយុទ្ធគ្នានេះមិនទៀងទេ ជួនណាយើងដកថយទៅវិញទៅ ជួនណាយើងលើងទៅព្រោះវាអត់ទៀងទេរឿងប្រយុទ្ធនេះ ដូចថាភាគអញ្ចឹងទៅយើងថយក្រោយហើយអត់មានទៅមុខរហូតទេ។

ធីតាៈ ថយក្រោយនៅពេលណាអ៊ំ?

ពិលៈ នៅពេលដែលកម្លាំងគេខ្លាំងគេច្រើនយើងថយទៅ ។

ធីតាៈ កម្លាំងគេប៉ុន្មានទៅ?

ពិលៈ កម្លាំងគេខ្លាំងតែមិនប្រាកដទេដូនកាលគេវ៉ៃខ្ទេចខ្ទីអស់ ។

ធីតាៈ អញ្ចឹងអ៊ំដូចថាកម្លាំងខ្លាំងដែលច្រើនហ្នឹងវ៉ៃពីខាងស្រុកស្វាយចេកហ្នឹងម៉ោទល់មុខគ្នាហ្នុង?

ពិលៈ បាទ!

ធីតាៈ អត់មានកាំភ្លើង អត់មានពូកេបាញ់គ្រាប់កាំភ្លើងធុងធាំងអីទេ?

ពិលៈ ពូខ្លាំងណាស់ ។

ធីតាៈ ពូពេញព្រៃពេញអីហ្នឹងហ្នុង?

ពិលៈ បើអាគោរស់វាដាក់កាណុងឯងគេចឡើងរេ ខាងរដ្ឋកម្ពុជា ។

ធីតាៈ កាណុងអីគេអ៊ំ?

ពិលៈ កាណុងខាងរដ្ឋកម្ពុជា ដែលគេដាក់សំណូក អាហ្នឹង៨០មីលីម៉ែតហើយ ។

ធីតាៈ អាហ្នឹងកាំភ្លើងម៉ាកវា៨០?

ពិលៈ ម៉ាកវា៨០ ។

ធីតាៈ អត់មានអាការឈ្មោះអីចឹងទេ?

ពិលៈ មានតែឈ្មោះ៦០មីលីម៉ែត ។

ធីតាៈ ៦០ហើយអីទៀត?

ពិលៈ មានតែអាការ ។

ធីតាៈ ចុះខាងទ័ពសឹន សានអីអ៊ំ

ពិលៈ សឹន សាន?

ធីតាៈ ចា៎! អាហ្នឹងម៉េចវិញអ៊ំ?

ពិលៈ ដល់សម្តេចតាបង្រួបបង្រួមគ្នាក៏បានជួបជុំគ្នា ។

ធីតាៈ ចប់ត្រឹមឆ្នាំណា?

ពិលៈ ចប់នៅឆ្នាំ៩៣ ។

ធីតាៈ ចុះ៨០អ៊ំនៅតែវ៉ៃគ្នាដដែល?

ពិលៈ វ៉ៃដដែល ។

ធីតាៈ វ៉ៃរហូតដល់៩៣ហ្នឹង?

ពិលៈ ដល់គេបង្រួបបង្រួមទៅចប់ទៅ ។

ធីតាៈ ចុះកាល៨៥,៨៦គេវៃម៉េចខ្លះទៅ?

ពិលៈ គេវៃគ្នាច្រើនណាស់តែភ្លេចអស់ហើយ ឆ្លងចេញឆ្លងចូលអាគេដាក់ឯង ឯងដាក់គេ បើគិតទៅខ្មែរតែមួយគត់តែវៃគ្នា ដល់ហើយម៉ោជួបជុំគ្នាទៅក៏ចប់ទៅ ។

ធីតាៈ អញ្ចឹងអ៊ំចង់បញ្ជាក់បន្តិចកាលឆ្នាំ៨០ហ្នឹងវៃម៉េចខ្លះទៅអ៊ំ សូមអ៊ំជួយបញ្ជាក់បន្តិចបានទេ?

ពិលៈ កាំភ្លើងមែន?

ធីតាៈ ចា៎! ដូចថាឆ្នាំ៨០ហ្នឹងម៉េចខ្លះនៅវៃគ្នាទៀតឬក៏ម៉េច?

ពិលៈ កាលឆ្នាំ១៩៨០ហ្នឹងវៃគ្នា ។

ធីតាៈ វៃគ្នា?

ពិលៈ ដល់វៃទៅវៃម៉ោមានខ្មែរក្រហមផងប៉ារ៉ាផងមានយួនផង វៃដល់ឆ្នាំ៨៩ ។

ធីតាៈ អញ្ចឹងអ៊ំនៅតែស្រុកស្វាយចេកហ្នឹងទេ?

ពិលៈ ជួនណាខ្ញុំនៅស្វាយចេក ជួនណាខ្ញុំនៅថ្មពួក ។

ធីតាៈ ហើយទ័ពអីមានស្លាប់មនុស្សច្រើនអត់អ៊ំ?

ពិលៈ មានស្លាប់មានរបួស ដាច់ជើងខ្លះអីខ្លះទៅ ។

ធីតាៈ របួសដាច់ជើង?

ពិលៈ ដាច់ជើងខ្លះ មានស្លាប់ខ្លះ ធម្មតាតែសង្គ្រាមមានស្លាប់មានរបួសហើយ ។

ធីតាៈ ចុះអ្នកដែលទៅជាមួយអ៊ំហ្នឹងមានអ្នកណាខ្លះដែលនៅរស់?

ពិលៈ ថាម៉េច?

ធីតាៈ ដូចថាអ្នកទៅប្រយុទ្ធហ្នឹងមានអ្នកណាខ្លះដែលនៅរស់ ដូចថាក្នុងចំណោមអ៊ំប៉ុន្មាននាក់អញ្ចឹងណា៎?

ពិលៈ មិនចាំទេព្រោះយើងបែកបាក់គ្នាអស់ហើយ វាភ្លេចឈ្មោះអស់ហើយ ខ្ញុំរំសាយហើយអារឿងទាហានហ្នឹង ឈប់មានអារម្មណ៍ថាចង់ធ្វើទាហានទៀតទេ អ្នកណាស្លាប់អ្នកណារបួសក៏ភ្លេចមុខអស់ហើយ ព្រោះវាដល់អាយុរំសាយហើយ កាលខ្ញុំរំសាយនៅឆ្នាំ២០០១ ។

ធីតាៈ ចុះកាល៩៣ហ្នឹងម៉េចខ្លះទៅ សុំអ៊ំជួយរៀបរាប់បានទេ?

ពិលៈ កាល៩៣?

ធីតាៈ ចា៎!

ពិលៈ កាលហ្នឹងបោះឆ្នោត ។

ធីតាៈ កាលពេលគេបោះឆ្នោតហើយកាលហ្នឹងគេដកទ័ពម៉េចខ្លះ?

ពិលៈ កាលពេលបោះឆ្នោតហ្នឹងទ័ពវានៅរាងខ្លួនអត់មានបញ្ហាទេ មិនថាទ័ពខ្មែរក្រហម មិនថាទ័ពរដ្ឋកម្ពុជា មិនថាទ័ពប៉ុរ៉ាទេដោះស្រាយដោយធម្មតា ។

ធីតាៈ ហើយមានបានទទួលដូចថាទទួលសម្តេចទទួលអីទេ?

ពិលៈ សម្តេចអត់មានបានទៅទទួលទេ ហើយអារឿងសម្តេចចេះតែគោរព ។

ធីតាៈ អ៊ីដូចថាពេលហ្នឹងអត់ទាន់ចប់អីណាក្នុងឆ្នាំ៨១អីហ្នឹង?

ពិលៈ ក្នុងឆ្នាំ៨១ហ្នឹងកំពុងតែពេញវ៉ៃគ្នាណា៎

ធីតាៈ ពេញម៉េចខ្លះទៅអ៊ី?

ពិលៈ យើងវ៉ៃគ្នាណា៎ ប៉ុរ៉ា ខ្មែរក្រហម យួនវ៉ៃគ្នាណា៎ ប៉ុរ៉ាប៉ះយួនក៏វ៉ៃ ប៉ុរ៉ាប៉ះខ្មែរក្រហមក៏វ៉ៃ ខ្មែរក្រហមប៉ះយួនក៏វ៉ៃ ដូចថាសង្គ្រាមណា៎ប៉ះអ្នកណាវ៉ៃអ្នកហ្នឹង កាលហ្នឹងវាមាន៣ប្រភេទ ។

ធីតាៈ ៣ប្រភេទហ្នឹងស្អីគេទៅ?

ពិលៈ មានប្រភេទទ័ពយួន ប្រភេទទ័ពប៉ុរ៉ា ប្រភេទទ័ពខ្មែរក្រហម អាណាប៉ះអាណាក៏វ៉ៃដែរ គាត់មួយនោះនិយាយរឿងគាត់មួយហ្នឹងគឺអត់មានដឹងថាអ្នកណាខ្មែរយ៉ាងណាអ្នកណាយ៉ាងណានោះទេ តែបើជួបជុំគ្នាសុទ្ធតែគ្នាឯងនោះទេ ដល់ពេលក្រោយម៉ោបានសម្រុះសម្រួលគ្នាទៅបានចប់ទៅ ។

ធីតាៈ ចុះក្រោយពីហ្នឹង ដូចថារយៈពេលយ៉ាងម៉េចទៅអ៊ី រយៈដែលអ៊ីវ៉ៃហើយ ហើយមានរយៈពេលប៉ុន្មានដែលថាបានសម្រាក ហើយអ៊ីមានចូលជំរុំចូលអីអត់?

ពិលៈ ចូលជំរុំដែរ ។

ធីតាៈ ជំរុំអីគេអ៊ី ហើយចូលនៅឆ្នាំណា?

ពិលៈ កាលហ្នឹងចូលជំរុំសាយធូ ដូចជាឆ្នាំ៧៧,៧៩ ដល់វ៉ៃគ្នារួចថយម៉ោសម្រាកនៅជំរុំ ហើយមានដូរគ្នាមួយខែម្នាក់ក្នុងមួយកង១ ។

ធីតាៈ ជំរុំសាយធូ?

ពិលៈ បាទ!

ធីតាៈ សាយធូហ្នឹងខាងអីគេ គេហៅអីគេអាហ្នឹង?

ពិលៈ មុនដំបូងគេហៅជំរុំថ្មី ដល់ពេលយួនវ៉ៃបែកម៉ោគេហៅជំរុំសាយធូ ។

ធីតាៈ ខាងជំរុំហ្នឹងមនុស្សរស់នៅណា៎អ៊ី ?

ពិលៈ ប្រហែលជា៣ម៉ឺនជាង ។

ធីតាៈ នៅជំរុំសាយធូហ្នឹងមែន?

ពិលៈ បាទ! កាលលើកមុនដូចជា៦ម៉ឺននាក់ ច្រើនណាស់តែខ្ញុំមិនដឹងរឿងគេផង កាលហ្នឹងបើមិន៨ម៉ឺន៦ម៉ឺន ទៅសួរគេដែលធ្វើការតាមសង្កាត់ហ្នឹងបានដឹង សួរប្រធានរដ្ឋបាលគេបានយល់ បើស្រុកកាលហ្នឹង២ជំរុំ៣ជំរុំ បើសាយធូនេះវា២គីឡូ៤ជ្រុងទេបើតាមមើល ។

ធីតាៈ កាលពីមុនឬក៏ឥលូវ?

ពិលៈ ប្រហែលជាសព្វថ្ងៃគេនេះអស់ហើយ ។

ធីតាៈ អញ្ចឹងអ៊ំនៅជុំរុំហ្នឹងបានយូដែរ?

ពិលៈ នៅបាន១២ខែ ។

ធីតាៈ ចុះម៉េចបានជាគេយកជំរុំសាយធូម៉ោចូលខាងហ្នឹងអញ្ចឹងអ៊ំ?

ពិលៈ ដើម្បីសន្តិភាពខ្មែរគេដាក់ម៉ោ កាលហ្នឹងអង្គការគេជួយ ។

ធីតាៈ អង្គការណាដែលជួយ?

ពិលៈ មិនដឹងអង្គការណាផង កាលហ្នឹងគេជួយរបស់របរម៉ោ កាលហ្នឹងក្នុងមួយនាក់ឲ្យប៉ុន្មានដុល្លាទេព្រោះចាំអត់បានវាភ្លេចអស់ហើយ ។

ធីតាៈ អញ្ចឹងអ៊ំសុទ្ធតែជាអ្នកជំរុំ?

ពិលៈ កាលនោះ១ដុល្លា២៥ ។

ធីតាៈ ហើយដល់ពេលត្រលប់ម៉ោវិញអ៊ំម៉ោរស់នៅភូមិហ្នឹងរហូតហ្មង?

ពិលៈ បាទ!

ធីតាៈ ចុះកាលពីមុនភូមិហ្នឹងកកើតម៉េចខ្លះទៅកាលពូម៉ោហ្នឹង ហើយឆ្នាំប៉ុន្មានដែលពូត្រលប់ម៉ោវិញ?

ពិលៈ ឆ្នាំ៩៣ ។

ធីតាៈ ចុះអ៊ំមានដែលឮឈ្មោះតាពិនទេ អត់ដែលស្គាល់ទេអ្នកនៅភូមិនេះ?

ពិលៈ តាពិនណា?

ធីតាៈ ឌុចណា៎?

ពិលៈ ឌុចហ្នឹងដាក់លើឯកសារ ។

ធីតាៈ តែអ៊ំមានដែលបានស្គាល់ទេ?

ពិលៈ អត់ទេមិនដែលបានស្គាល់គាត់ផង ។

ធីតាៈ ចុះដូចថាឥលូវមានតុលាការមានអីអញ្ចឹងណា៎ អ៊ំចង់តុលាការកាត់ទោសមេដឹកនាំកាន់តែឆាប់អត់?

ពិលៈ ចង់ឲ្យគេកាត់ទោសកាន់តែឆាប់ព្រោះកុំឲ្យរឿងហ្នឹងវានៅស្រពិចស្រពិល សព្វថ្ងៃនៅតែអល់ឯក ។

ធីតាៈ អល់ឯកយ៉ាងម៉េចខ្លះ?

ពិលៈ អាកាត់មិនកាត់ថាមិនកាត់មិនកាត់ វានៅអល់ឯកត្រង់ហ្នឹងស្មើតែកាត់ហើយស្មើរតែមិនកាត់ ។

ធីតាៈ ចាំ! ចុះអ៊ីដូចថាឥលូវក្រោយ៧៩តើអ៊ីយល់ឃើញយ៉ាងម៉េចដែរ ទិដ្ឋភាពឥលូវហើយកាលពីមុនខុសគ្នាយ៉ាងម៉េចខ្លះ?

ពិលៈ ខុសគ្នាឆ្ងាយណាស់ ។

ធីតាៈ ខុសគ្នាយ៉ាងម៉េច?

ពិលៈ ឥលូវវាមានការអភិវឌ្ឍន៍ ហើយពីមុនវេទនាណាស់ប្រជាជននៅក្នុងប្រទេសជួបការលំបាកខ្វះការស្លៀកពាក់ ស៊ីចុកអីទាំងអស់ហ្នឹង ហើយម៉ោដល់សព្វបងប្អូនមានជីវភាពគ្រប់គ្រាន់ហើយតែគ្រប់គ្រាន់តែអ្នកនៅនោះទេ តែបើអ្នកនៅជនបទមិនគ្រប់គ្រាន់ព្រោះវានៅវាងយ៉ាប់យឺនណាស់ សព្វថ្ងៃគេអភិវឌ្ឍន៍តែទីក្រុងទេ តែនៅជនបទមិនសូវឃើញគេអភិវឌ្ឍន៍ប៉ុន្មានផង ការដោះស្រាយជីវភាពគ្រួសារគឺមានតែនៅទីក្រុងទេ នៅជនបទគ្មានអ្នកណាជួយដោះស្រាយទេ ។

ធីតាៈ ចុះឥលូវអ៊ីមានកូនប៉ុន្មាននាក់ហើយ?

ពិលៈ កូន៤នាក់ ។

ធីតាៈ ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ពិលៈ ស្រី២នាក់ ប្រុស២នាក់ ។

ធីតាៈ ចុះអ៊ីបានការជាមួយអ៊ំស្រីតាំងពីឆ្នាំណាដែរ?

ពិលៈ ឆ្នាំ៧៩ ។

ធីតាៈ ៧៩ហ្នឹងពេលត្រលប់ម៉ោវិញ?

ពិលៈ ហ្នឹងអើយ ។

ធីតាៈ ហេតុអីបានជាបានគ្នា ដោយសារមូលហេតុអី ស្គាល់គ្នាឬក៏ម៉េច?

ពិលៈ ស្រលាញ់គ្នា ។

ធីតាៈ គាត់អ្នកស្រលាញ់ ហើយគាត់អ្នកស្រុកភូមិហ្នឹងដែរ?

ពិលៈ គាត់អ្នកស្រុកភូមិនេះហើយខ្ញុំចូលម៉ោឃើញស្រលាញ់គ្នាហ្មង កាលខ្ញុំម៉ោពីស្រុកថៃ ។

ធីតាៈ អ៊ំ! អញ្ចឹងកាលអ៊ីចូលម៉ោពីស្រុកថៃហ្នឹងកាល៧៩ ហើយអ៊ីទៅធ្វើទាហាននៅស្វាយចេកទៀតអញ្ចឹងមែន?

ពិលៈ អត់ទេកាលហ្នឹងខ្ញុំម៉ោវិញខ្ញុំទៅធ្វើទាហាននៅស្វាយចេក ហើយកាលហ្នឹងទៅនៅដំរុំ ហើយទៅនៅព្រៃទៀត ។

ធីតាៈ កាលហ្នឹងសំបូរព្រៃ?

ពិលៈ ហ្នឹងអើយកាលហ្នឹងសុទ្ធតែព្រៃ ។

ធីតាៈ អញ្ចឹងអ៊ំមានអ៊ីចង់បន្ថែមទៀតទេអ៊ំ?

ពិលៈ អត់មានអីទេ តែបើបន្ថែមទៅវាអាចចាកប្រធានក៏ថាបាន សុំឲ្យនាងជួយទាក់ទងព្រោះអ្នកនៅក្នុងភូមិវាកំពុងតែមានការខ្វះខាត គ្រាន់តែវាការប្រមូលភោគផលប៉ុណ្ណឹងវាមិនគ្រប់គ្រាន់ទេ ។

ធីតាៈ អញ្ចឹងអរគុណច្រើនណ៎អ៊ំ ។

ពិលៈ បាទ!

«ចប់»